# ឯកសារដាក់ជូនក្រុមការងារមុនពេលការប្រជុំ
# ស្តីពី
# អនុសញ្ញាលុបបំបាត់ការរើសអើងលើនារីភេទ

## ការណែនាំ

១. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងលើនារីភេទ (NGO-CEDAW) ដែលមានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងក្រៅស្រុក ចំនួន ៧២ អង្គការ ដែលកំពុងធ្វើការលើកកម្ពស់សមភាពរវាងបុរស និងស្ត្រី និងគាំទ្រចំពោះការលុបបំបាត់ការរើសអើងលើនារីភេទ។ នៅក្នុងការប្រជុំកន្លងទៅថ្មីនេះ សមាជិកបានលើកឡើងនូវការព្រួយបារម្ភមួយចំនួនខាងក្រោម ដើម្បីឲ្យមានការពិចារណា ដោយគណៈកម្មាធិការរបស់អង្គការសហប្រជាជាតិទទួលបន្ទុក (គណៈកម្មាធិការ CEDAW)។ ការព្រួយបារម្ភ ទាំងនេះ ត្រូវបានលើកឡើងបន្ថែម និងដើម្បីកំណត់បញ្ហាអាទិភាព ដែលបញ្ហាទាំងនេះមានរៀបរាប់ លំអិតនៅក្នុងរបាយការណ៍ស្រមោល ធ្វើឡើងដោយ NGO-CEDAW កាលពីខែមីនា ឆ្នាំ២០១១ កន្លង ទៅ។

២. ព័ត៌មានបន្ថែម ករណីសិក្សានានា និងឯកសារយោងជាច្រើន នឹងត្រូវបានបង្ហាញ នៅមុនពេលនៃសម័យប្រជុំលើកទី៥៦ នៃគណៈកម្មាធិការ CEDAW នៅខែតុលា ឆ្នាំ២០១៣ ខាងមុខ។

## មាត្រា ១ & ២

៣. ក្នុងខណៈពេល ដែលយើងធ្វើការស្វាគមន៍ចំពោះការពង្រឹងច្បាប់ នៅក្នុងវិស័យជាក់លាក់មួយចំនួន យើងមានការព្រួយបារម្ភថា (ស្របជាមួយការបូកសរុបអនុសាសន៍របស់អង្គការសហប្រជាជាតិ វាក្យខ័ណ្ឌ១២) កម្ពុជាមិនទាន់មានការកំណត់និយមន័យអំពីពាក្យនៃការរើសអើងនៅក្នុងច្បាប់ ដែល ហ៊ុមព័ទ្ធទាំងការរើសអើងដោយផ្ទាល់ និងដោយប្រយោល ស្របជាមួយមាត្រា១ នៃអនុសញ្ញា CEDAW នេះ។

៤. ទោះបីមានការកែលំអ ដោយផ្តោតលើការត្រួតពិនិត្យជាក់លាក់ទៅលើសិទ្ធិមនុស្សរបស់ស្ត្រី និង សូចនាករ ដែលបានបង្កើតឡើងនៅក្នុងវិស័យមួយចំនួនក៏ដោយ ព័ត៌មាន និងស្ថិតិទាំងនេះ នៅមិនទាន់ មាន ឬមានការពិបាកក្នុងការទទួលបាន។ បញ្ហានេះ រួមបញ្ចូលទាំងព័ត៌មានអំពីការកំណត់ថវិកា ដែល ទាក់ទងនឹងការបញ្ជ្រាបយេនឌ័រ ឬ វិស័យជាក់លាក់ទៅលើផ្នែកយេនឌ័រដទៃទៀត (ការអំណះអំណាង បូកសរុបអនុសាសន៍នានារបស់អង្គការសហប្រជាជាតិ វាក្យខ័ណ្ឌ ១៤)។

## មាត្រា ៥

៥. ថ្វីត្បិតតែ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ នៅឆ្នាំ២០០៥ គឺពិតជាជំហានឆ្ពោះទៅមុខប្រកបដោយ វិជ្ជមានមួយក៏ដោយ តែការអនុវត្តន៍ច្បាប់នេះ គឺនៅមាន ភាពទន់ខ្សោយនៅឡើយ។ មានឧបសគ្គធំៗចំពោះស្ត្រី ក្នុងការទទួលបានយុត្តិធម៌។ ជាញឹកញាប់មាន ការចំណាយថវិកាជាច្រើន (ទាំងផ្លូវការ និងក្រៅផ្លូវការ) ដើម្បីឲ្យមានការដោះស្រាយសំណុំរឿង។ ដំណើរការផ្សះផ្សានៅតាមមូលដ្ឋាន ជារឿយៗមានការរើស អើងលើស្ត្រីជាមួយសំពាធ ដែលបានដាក់ដោយ មិនត្រឹមត្រូវ ដើម្បីអោយគាត់បន្តការរស់នៅជាមួយដៃគូ ដែលប្រើអំពើហិង្សាទៅលើអ្នកទាំងនោះ។ ទោះបីមានការវិវឌ្ឍន៍ ខ្លះៗក៏ដោយតែអត្រាអំពើហិង្សា និងការទទួលយកនូវភាពហិង្សានៅតែមាន កម្រិតខ្ពស់។

៦. ការអនុវត្តន៍ច្បាប់ព្រហ្មទណ្ឌក៏នៅមានភាពទន់ខ្សោយនៅឡើយ ហើយជនប្រព្រឹត្តិបទល្មើសអំពើហិង្សា លើយេនឌ័រជាច្រើន ត្រូវបានគេអនុញ្ញាតឲ្យដោះស្រាយ ដោយធ្វើការរៀបចំសំណងជាប្រាក់ តិចតួចទៅឲ្យជនរងគ្រោះ ឬ គ្រួសាររបស់ជនរងគ្រោះ ហើយបន្ទាប់មកគ្រួសាររបស់ជនរងគ្រោះនឹង ដកពាក្យបណ្តឹង។ នៅក្នុងសំណុំរឿងខ្លះ តុលាការនឹងលើកលែងការចោទប្រកាន់ (និទ្ទណ្ឌភាព)។ សំណុំរឿងចាប់រំលោភទំនងជាមានការកើនឡើង ដោយការកើតមានឡើងនូវការករណីរំលោភជំរុកគួន ដែលបានបប្រព្រឹត្តិទៅលើ ក្មេងស្រីដែលស្ថិតនៅក្នុងវ័យពី ៣ ទៅ ៤ ឆ្នាំ។

## មាត្រា ៦

៧. រដ្ឋាភិបាល បានស្វាគមន៍នូវកិច្ចខិតខំប្រឹងប្រែងទៅលើការកាត់បន្ថយការជួញដូរ នៅក្នុងការសហការជាមួយដៃគូនានានៅក្នុងតំបន់ ដោយផ្តោតលើការជួញដូរក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ។ ថ្វីបើបញ្ហានេះ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍របស់រដ្ឋាភិបាលទៅកាន់គណៈកម្មាធិការ CEDAW (វាក្យខ័ណ្ឌ ១០៣) ក៏ដោយ តែការកេងប្រវ័ញ្ចផ្លូវភេទនៅបន្តកើតឡើង ដូច្នេះ សូមឲ្យមានការបន្តប្រឹងប្រែងដោះស្រាយអោយកាន់តែខ្លាំង និងសូមឲ្យមានការផ្តល់ធនធាននានាដែលចាំបាច់។ បន្ថែមពីលើនេះ អ្នកធ្វើចំណាកស្រុកដើម្បីស្វែងរកការងារ នៅតែងាយរងគ្រោះខ្លាំងជាមួយបណ្តាក្រុមហ៊ុន ដែលចែងបទបញ្ជាផ្ទៃក្នុងមិន ត្រឹមត្រូវ ហើយជារឿយៗ ស្ត្រី ឬ ក្មេងស្រី ត្រូវបានគេជ្រើសរើសចេញមកពីតំបន់ជន បទក្រីក្រ។ ការត្រួតពិនិត្យ និងការងារលើផ្នែកនេះ គួរតែអនុវត្តអោយកាន់តែប្រសើរឡើងនូវច្បាប់បញ្ញត្តិ នៅតាមថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដូច្នេះ តម្រូវការធនធាន និងកិច្ចព្រមព្រៀងបន្ថែមនៅថ្នាក់តំបន់ គឺមានសារៈសំខាន់ណាស់។

## មាត្រា ៧

៨. ចំពោះចំនួននៃស្ត្រី ដែលកាន់មុខតំណែងសាធារណៈ បានកើនឡើងជាបន្តបន្ទាប់ តែតួលេខបច្ចុប្បន្នបង្ហាញឱ្យឃើញពីការបន្ថយល្បឿន នៅក្នុងកំណើននេះ ក្នុងខណៈដែលការតំណាងជាទូទៅរបស់ស្ត្រីនៅមានកម្រិតទាបខ្លាំងនៅឡើយ។ មានការស្នើឡើងថា កូតាសម្រាប់ស្ត្រីកាន់មុខតំណែងនៅកម្រិត ផ្សេងៗ

ត្រូវតែបង្កើន ហើយគួរតែមានសកម្មភាពវិជ្ជមានបន្ថែម ដើម្បីបណ្តុះបណ្តាល និងលើកទឹកចិត្ត ដល់បេក្ខភាពនារី។

៩. ចំពោះស្ត្រីមួយចំនួនដែលមានតំណែងក្នុងជួររដ្ឋាភិបាល គឺពួកអ្នកទាំងនោះ បានជួបប្រទះនូវការរើសអើងពីឋានៈ តួនាទីផ្សេងគ្នា និងធ្វើការរំពឹងទុកជាងសហសេវិកជាបុរស។ កិច្ចប្រឹងប្រែងជាក់លាក់ ដើម្បីតបតនឹងការរើសអើងនេះគឺ ចាំបាច់ត្រូវធ្វើឡើង ដោយរួមបញ្ចូលទាំងការអប់រំដល់បុរស និងស្ត្រីព្រមទាំងបណ្តាញចំរុះរបស់ស្ត្រីនៅគ្រប់កម្រិត។ បណ្តុំគោលការណ៍ និងគោលនយោបាយជាក់លាក់អំពីការបង្កើនការចូលរួមរបស់ស្ត្រី និងភាពជាអ្នកដឹកនាំត្រូវបានគេស្នើឱ្យមានធ្វើឡើង។

**មាត្រា ១០**

១០. នៅមានសមភាពយេនឌ័រ ត្រឹមកម្រិតមតេយ្យសាលា និងបឋមសិក្សា ហើយមានការកើនឡើង នៅកម្រិតមធ្យមសិក្សា។ វិសមភាពនៅតែមាន ជាពិសេសនៅក្នុងការអប់រំកម្រិតខ្ពស់ ហើយមាន តួលេខលំអិតច្រើនទៀតលើអាយុ ដែលនឹងត្រូវទទួលបានអាហារូបករណ៍។ យើងសូមស្នើឡើងអោយ មានការបង្កើននូវអាហារូបករណ៍ និងការគាំទ្រ (ដូចជា ការផ្តល់អន្តេវាសិកដ្ឋាន ដោយឥតគិតថ្លៃសម្រាប់ ក្មេងស្រី) ដល់ស្ត្រីគ្រប់វ័យ និងដោយឡែកសម្រាប់ស្ត្រីវ័យចំណាស់។

១១. ចំនួនសាលារៀនបានកើនឡើង ទោះបីជាតួលេខទាក់ទងទៅនឹងកម្រិតប្រជាជនមានកើនឡើង ហើយសមត្ថភាពជារួមក្នុងការបង្កើនចំនួនសាលារៀន ពិតជាវិធានការដ៏មានសារប្រយោជន៍ច្រើន។ មានការព្រួយបារម្ភមួយថា សិទ្ធិទទួលបានការអប់រំនៅតំបន់ដាច់ស្រយាលជាច្រើននៅតែមានការលំបាក ហើយលទ្ធភាពដែលអាចទទួលបាន និងការផ្តល់នូវមធ្យោបាយធ្វើដំណើរ ដោយសុវត្ថិភាពទៅសាលារៀនបានរារាំងក្មេងស្រីក្នុងការចូលរួមទទួលយកនូវការអប់រំ ដោយមិនមានសមាមាត្រ។ យើងក៏សូម ធ្វើការស្នើឡើងអោយមានការបង្កើនចំនួន និងការទទួលបាននូវទីកន្លែងសិក្សានៅគ្រប់កម្រិត ចាប់ពី មត្តេយ្យសាលានៅតំបន់ដាច់ស្រយាល។ សូចនាករ ដែលត្រូវបានបង្កើតឡើង និងត្រូវបានត្រួតពិនិត្យ ដើម្បីបង្ហាញអំពីការរីកចម្រើននូវឱកាសទទួលបានការសិក្សានៅតាមស្រុក។

១២. ប្រាក់បៀវត្សរ៍គ្រូបង្រៀនទាប បន្តធ្វើឱ្យគុណភាពនៃការអប់រំមិនល្អ និងនាំឱ្យមានការយកកម្រៃបន្ថែមពីសិស្ស។

**មាត្រា ១១**

១៣. ដូចមានចែងនៅក្នុងមាត្រា៦ សុវត្ថិភាព នៃជនចំណាកស្រុកដើម្បីស្វែងរកការងារ គឺជាការព្រួយបារម្ភមួយ (ជាពិសេសមានចំនួនអ្នកធ្វើចំណាកស្រុកភាគច្រើនទៅប្រទេសម៉ាឡេស៊ី ដែលអ្នកទាំងនោះ ចំណាកស្រុកដោយមិនមានការទទួលស្គាល់ និងអនុញ្ញាតពីរដ្ឋាភិបាល។ មានឧទាហរណ៍ នៃការ រំលោភបំពានជាច្រើន ដែលរកឃើញដោយស្ថាប័នសិទ្ធិមនុស្ស និងបុគ្គលិករដ្ឋាភិបាលមួយចំនួន ដែល ត្រូវបានចាត់តាំងអោយទៅការពារសិទ្ធិជនចំណាកស្រុកទាំងនោះ គឺនៅតែមិនទាន់គ្រប់គ្រាន់នៅឡើយ។ ការធ្វើ

អនុស្សរណៈនៃការយោគយល់បន្ថែម ជាមួយនឹងប្រទេសដទៃទៀតនៅក្នុងតំបន់ និងការចូលរួមពី ក្រុមហ៊ុនឯកជន អាចធ្វើអោយកាន់តែប្រាកដថា សិទ្ធិមនុស្សរបស់ស្ត្រីត្រូវបានការពារ។

១៤. ខណៈពេល ដែលយើងស្វាគមន៍ ចំពោះការកែលំអច្បាប់ និងកិច្ចការពារស្ត្រី ការផ្លាស់ប្តូរបន្ថែមទៀត គួរតែធ្វើឡើងនៅក្នុងវិស័យមួយចំនួនដើម្បីពង្រឹង និងធ្វើអោយប្រសើរឡើងនូវកិច្ចការពារចំពោះលក្ខខណ្ឌនៃការងារ។ ដោយឡែកការពង្រឹងការអនុវត្តន៍លក្ខខណ្ឌសុខភាពសុវត្ថិភាព នៅតាមបណ្តារោងចក្រនៅមានភាពទន់ខ្សោយនៅឡើយ ដែលធ្វើឱ្យមានផលប៉ះពាល់មិនស្មើរគ្នាមកលើស្ត្រី ដោយសារតែចំនួនកម្មករជាស្ត្រីមានច្រើនលើសលុបនៅក្នុងបណ្តារោងចក្រទាំងនេះ។

១៥. បើមានការឈានទៅរកផ្តល់សច្ចាប័នអនុសញ្ញាលេខ ១៨១ របស់អង្គការពលកម្មអន្តរជាតិ (ភ្នាក់ងារការងារ និងមុខរបរឯកជន) អនុសញ្ញាលេខ១៨៣ (កិច្ចគាំពារមាតុភាព) និងអនុសញ្ញាលេខ ១៨៩ (កម្មករបម្រើការងារតាមផ្ទះ) និងអនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារពលករចំណាកស្រុក និងក្រុមគ្រួសាររបស់ពួកគេនោះ នឹងអាចពង្រឹងសិទ្ធិមនុស្សរបស់ស្ត្រីជាសំខាន់។ ស្ថាប័នសិទ្ធិមនុស្ស និងសហាជីពមើលឃើញមានករណីរំលោភសិទ្ធិនៅក្នុងវិស័យទាំងនេះជាញឹកញាប់ (រដ្ឋាភិបាលកម្ពុជាបានប្រកាសផ្អាកមួយរយៈការបញ្ជូនពលករបម្រើការតាមផ្ទះទៅប្រទេសម៉ាឡេស៊ី។ ការផ្អាកនេះ មិនបានដោះស្រាយហេតុការណ៍ ដែលពលករបម្រើការតាមផ្ទះមួយចំនួន កំពុងបានរស់នៅប្រទេសម៉ាឡេស៊ីរួចហើយនោះត្រូវបានគេបង្ខំ អោយបន្តកិច្ចសន្យាការងារ ដែលផ្ទុយពីឆន្ទៈរបស់ពួកគេ)។

១៦. ជាលក្ខណៈប្រពៃណី ការងារកសិកម្ម ត្រូវចាត់តាំងថា ជាការងាររបស់បុរស បើទោះបីជាមាន ការចូលរួមរបស់ស្ត្រីមានកម្រិតខ្ពស់នៅក្នុងការងារកសិកម្ម និងមានស្ត្រីជាច្រើន ដែលធ្វើការងារផ្ទះនៅ តំបន់ជនបទដាច់ស្រយាលក៏ដោយ។ យុទ្ធសាស្ត្រជាក់លាក់ ដើម្បីពង្រឹងទីផ្សារ ការសម្របសម្រួលចូល ទីផ្សារ និងជំនាញបច្ចេកទេសសម្រាប់ស្ត្រីនៅក្នុងតំបន់ទាំងនេះ នឹងត្រូវបានស្វាគមន៍។

## មាត្រា ១២

១៧. របាយការណ៍រដ្ឋាភិបាលបានទទួលស្គាល់ការរីកចម្រើនជាច្រើនគួរសម នៅក្នុងការថែទាំសុខភាព ក៏ដូចជា បញ្ហាប្រឈមមួយចំនួនធំ។ សេវាថែទាំសុខភាពនៅមានកម្រិត ជាពិសេសមានច្រើននៅតំបន់ដាច់ស្រយាល។ ឱកាសទទួលបានការថែទាំសុខភាពប្រឈមនឹងឧបសគ្គមួយចំនួន។ ថ្លៃធ្វើដំណើរទៅកាន់មណ្ឌលសុខភាព និងការយកកម្រៃផ្សេងៗ ទាំងផ្លូវការ រឺ ក្រៅផ្លូវការ ជាកត្តារារាំងស្ត្រីមួយចំនួនមិនឱ្យទទួលបានសេវាថែទាំសុខភាពត្រឹមត្រូវ។ មានគម្រោងសមធមិសុខភាព បានដំណើរការនៅក្នុងតំបន់មួយចំនួន ប៉ុន្តែជាធម្មតានៅតែពឹងលើទុនមួយចំនួន របស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីដំណើរការឱ្យមានប្រសិទ្ធិភាព។ ការផ្តល់ការដឹកជញ្ជូន ដោយឥតគិតថ្លៃ និងសេវាចល័តបន្ថែម ត្រូវបានស្នើឡើងបានបង្កើតចេញពីឧទាហរណ៍ ដែលជោគជ័យបំផុតក្នុងការអនុវត្តនៅក្នុងតំបន់មួយចំនួន។ ការត្រួតពិនិត្យដែលម៉ត់ចត់ និងមាំទាំនៃលទ្ធផលសុខភាពពិតជាមានសារប្រយោជន៍បន្ថែមទៅលើការស្រាវជ្រាវជា

ទៀងទាត់អំពីសុខភាព និងប្រជាសាស្ត្រ។ របាយការណ៍ដែលអាចរកបាន និងលំអិតទៅលើគម្រោង សមធម៌សុខភាព និងលទ្ធផលនានា ពិតជាផ្តល់ទាំងផលប្រយោជន៍ និងការណែនាំ។

១៨. គោលនយោបាយសម្រាប់ការថែទាំ និងការគាំទ្រដល់ស្ត្រីវ័យចំណាស់ ត្រូវបានគេពិចារណារឹតតែមានសារៈសំខាន់ ជាមួយការផ្លាស់ប្តូរប្រជាសាស្ត្រ និងការបំលាស់ទីដ៏ច្រើនរបស់ប្រជាពលរដ្ឋ រួមបញ្ចូលទាំងការផ្តល់ឱ្យ និងធនធានសម្រាប់សេវាថែទាំមនុស្សចាស់។

១៩. ការផ្តល់សេវាសុខភាព នៅតែជាការប្រឈមជាមួយករណីមួយចំនួន ដែលបានរាយការណ៍ពីអ្នកដែលគ្មានប្រាក់ គឺពេលខ្លះត្រូវបានគេបដិសេធមិនព្យាបាលឲ្យ។ មានករណីថ្មីៗមួយ ដែលស្ត្រីពេញវ័យម្នាក់ត្រូវបានគេទទួលសេវាសម្ភពមិនគ្រប់គ្រាន់ ហើយកូនរបស់គាត់បានសម្រាលនៅក្បែរ ផ្លូវរថភ្លើង។ ការទទួលខុសត្រូវ និងការត្រួតពិនិត្យសេវាសាធារណៈកាន់តែតឹងរឹងនៃសេវាសាធារណៈ គឺពិតជាត្រូវ ការចាំបាច់ក្នុងការអនុវត្តវិន័យអោយកាន់តែខ្ជាប់ខ្ជួន ចំពោះការរំលោភលើសេចក្តីទុកចិត្ត។

២០. ការប្រាស្រ័យទាក់ទង និងការសហការរវាងកម្មវិធីសុខភាពរបស់ NGO និងសេវាសុខភាពនៅតែទន់ខ្សោយ។ យើងបានស្នើសុំឱ្យរដ្ឋាភិបាល និងអង្គការ ដែលធ្វើការលើវិស័យនេះ យកចិត្តទុកដាក់ អោយកាន់តែខ្លាំងលើបញ្ហានេះ និងបង្កើតនូវគោលការណ៍ណែនាំ និងគោលនយោបាយនានាឱ្យបាន កាន់តែច្បាស់សម្រាប់កិច្ចសហការ។

**មាត្រា ១៣**

២១. ទីជនបទ ជាពិសេសតំបន់ទាំងឡាយ ដែលមានក្រុមប្រជាពលរដ្ឋ ដែលជាជនជាតិដើមភាគតិច រស់នៅច្រើន បន្តប្រឈមនឹងជម្លោះដ៏ធំ ទាក់ទងជាមួយនឹងដីសម្បទានសេដ្ឋកិច្ច (ELCs)។ ទោះបីមាន ការផ្អាកមិនឲ្យបន្តធ្វើសម្បទានដី ដែលត្រូវបានប្រកាស កាលពីខែឧសភា ឆ្នាំ២០១២ ក៏ដោយ នៅត្រឹម ខែធ្នូ ឆ្នាំ២០១២ យ៉ាងតិចណាស់មានដីចំនួន ២.៦៥៧.៤៧០ ហិចតា ដែលត្រូវបានគេធ្វើសម្បទាន ឬបំរុង ទុកឱ្យក្រុមហ៊ុនឯកជន មានកំណើន ១៦.៧% ពីឆ្នាំ២០១១ ។ ថ្វីបើរដ្ឋាភិបាលបានបង្កើនកម្មវិធីក្នុងការ ផ្តល់កម្មសិទ្ធិដីធ្លីយ៉ាងច្រើនគួរសមដល់ប្រជាពលរដ្ឋ តែការផ្តល់កម្មសិទ្ធិដីធ្លីនៅថ្នាក់មូលដ្ឋាន នៅតែ ដំណើរការយ៉ាងយឺត ហើយសហគមន៍ជនជាតិដើមភាគតិចជាច្រើន ដែលជាអ្នកបានដាក់សំណើនោះ បានប្រឈមដោយលំបាកណាស់ និងវិវាទជាមួយអាជ្ញាធរមូលដ្ឋានយ៉ាងខ្លាំងបំផុត។ ការផ្តល់ឱ្យនេះ បានប៉ះពាល់ដល់ភាពមិនស្មើរគ្នាទៅលើស្ត្រីតាមវិធីមួយចំនួន។ សហគមន៍នៅមូលដ្ឋានបានរាយការណ៍ ពីការកើនឡើងនូវអំពើហិង្សាទៅលើស្ត្រីដោយផ្អែកលើយេនឌ័រ ក៏កម្មករក្រុមហ៊ុនឯកជន ដែលបាន រឹតត្បិតសេរីភាពក្នុងការដើរហើររបស់ស្ត្រីទាំងនោះ។ ជាងនេះទៅទៀត ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីបាន បង្កើននូវសំពាធក្នុងការបោះបង់ចោលនូវវិធីសាស្ត្រទ្រទ្រង់កសិកម្មបែបប្រពៃណី ហើយជានិច្ចកាល ធ្វើអោយថយចុះកិច្ចសហការ និងសាមគ្គីភាពនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ព្រមទាំងធ្វើអោយ មានការកើនឡើងនូវវិសមភាពផងដែរ។

២២. វិវាទដីធ្លីកើនឡើងយ៉ាងខ្លាំងនៅក្នុងឆ្នាំ២០១២ ដែលភាគច្រើនស្ត្រីដែលតែងតែឈរនៅជួរមុខក្នុងការធ្វើការតវ៉ា និងទទួលរងការរំលោភបំពាន និងការចាប់ដាក់ពន្ធនាគារ ស្របពេលជាមួយនឹងការបាត់បង់ដីធ្លី និងជីវភាពរស់នៅ។

## បញ្ហាផ្សេងៗ

២៣. ថ្វីត្បិត ដែលស្ថានភាពរបស់ស្ត្រីពិការ និងស្ត្រីជនជាតិដើមភាគតិច ត្រូវបានដាក់បញ្ចូលនៅក្នុងរបាយការណ៍លំអិតមួយរបស់រដ្ឋាភិបាល ប៉ុន្តែបញ្ហាទាំងនេះ នៅតែមិនបានបង្ហាញឡើងនៅក្នុងតំបន់មួយចំនួន។ វាជួយឱ្យយើងមើលឃើញនូវព័ត៌មានច្រើន ជាពិសេសទាក់ទងនឹងការអប់រំ ការងារ និងការថែទាំសុខភាព ដែលជាការឆ្លើយតបទៅនឹងការសេចក្តីផ្តល់មតិ ចំនុចទី៣៦ (អនុសាសន៍របស់ គណៈកម្មាធិការរបស់អង្គការសហប្រជាជាតិទទួលបន្ទុក CEDAW) ព្រមទាំងទាក់ទងផងដែរទៅនឹង អំពើហិង្សាលើយេនឌ័រ ការចូលរួមក្នុងវិស័យនយោបាយ និងការដែលអាចទទួលបាននូវគ្រឹះស្ថាន សាធារណៈ (ឧ. សារមន្ទីរ បណ្ណាល័យ....)។